# អំពើរំលោភសេពសន្ថវៈ និង អំពើហិង្សាផ្លូវភេទ

## យល់ដឹងអំពីសិទ្ធិរបស់អ្នក



សុវត្ថិភាព និង យុត្តិធម៌

# តើអំពើរំលោភសេពសន្ថវៈ និង អំពើប្រទូស្តកេរខ្មាសជាអ្វី ?

អំពើរំលោភសេពសន្ថវៈ និងអំពើប្រទូស្តកេរខ្មាស ជាអំពើរំលោភសិទ្ធិមនុស្ស ។

១ **អំពើរំលោភសេពសន្ថវៈ៖**
សំដៅលើសកម្មភាពណាមួយនៃការជ្រៀតចូលផ្លូវភេទ ដោយគ្មានការសំដែងចេញនូវការយល់ព្រមពីបុគ្គលណាមួយ ដូចជាការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយការឆ្លៀតឱកាស ។

២ **អំពើប្រទូស្តកេរខ្មាស៖**
សំដៅលើសកម្មភាពណាមួយនៃការប៉ះពាល់កេរភេទ ឬផ្នែករាងកាយផ្សេងទៀតរបស់បុគ្គលម្នាក់ ដោយគ្មានការសម្តែងចេញនូវការយល់ព្រមពីបុគ្គលនោះ ឬជាការបង្ខិតបង្ខំបុគ្គលម្នាក់ឱ្យប្រព្រឹត្តអំពើបែបនេះលើអ្នកដទៃ ក្នុងគោលបំណងធ្វើឱ្យរំជើបរំជួលផ្លូវភេទរបស់ខ្លួន ។

## តើនរណាខ្លះរងផលប៉ះពាល់ ?

អំពើរំលោភសេពសន្ថវៈ និងអំពើប្រទូស្តកេរខ្មាស អាចត្រូវបានប្រព្រឹត្តិទៅលើមនុស្សគ្រប់គ្នា រួមមានស្ត្រី បុរស ក្មេងស្រី ក្មេងប្រុស និងក្រុមអ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI+) ។

## តើនរណាអាចជាជនល្មើស ?

បុគ្គលណាមួយ ក៏អាចជាជនល្មើស ។ គ្មាននរណាម្នាក់មានសិទ្ធិប្រព្រឹត្តអំពើនេះលើអ្នកឡើយ ទោះជាសមាជិកគ្រួសារ ប្តី ប្រពន្ធ មិត្តប្រុស ឬមិត្តស្រីរបស់អ្នក ។

# តើមានផលប៉ះពាល់អ្វីខ្លះ ?

អំពើរំលោភសេពសន្ថវៈ និងអំពើប្រទូស្តកេរខ្មាស អាចធ្វើឱ្យមានគ្រោះថ្នាក់ដល់រាងកាយ និងផ្លូវចិត្តភ្លាមៗ និងយូរអង្វែង ។ អំពើនេះ អាចប៉ះពាល់ដល់ការលូតលាស់ សុខភាពផ្លូវចិត្ត និងការសិក្សារបស់កុមារ ។

អំពើនេះ ក៏អាចបណ្តាលឱ្យស្ត្រី ឬក្មេងស្រី មានផ្ទៃពោះដែលខ្លួនមិនចង់បាន និងការឆ្លងជំងឺកាមរោគ ដែលត្រូវទទួលសេវាខាងវេជ្ជសាស្ត្រ ឱ្យបានឆាប់រហ័ស ។

**គ្មាននរណាម្នាក់សមនឹងទទួលរងនូវអំពើហិង្សាផ្លូវភេទនោះទេ ។**

# តើការរំលោភបំពានផ្លូវភេទ ជាអំពើខុសច្បាប់ឬទេ ?



ពិតណាស់ ! អំពើរំលោភសេពសន្ថវៈ និងអំពើប្រទូស្តកេរខ្មាស គឺជាអំពើខុសច្បាប់ ។

## ជនល្មើសអាចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារៈ

| បទល្មើស | ទោសពន្ធនាគារ | ក្រមព្រហ្មទណ្ឌ |
|---|---|---|
| បទរំលោភសេពសន្ថវៈ ឬ ប៉ុនប៉ងរំលោភសេពសន្ថវៈ | **៥ ដល់ ១០ ឆ្នាំ** | មាត្រា ២៣៩ |
| បទប្រទូស្តកេរខ្មាស ឬ ប៉ុនប៉ងប្រទូស្តកេរខ្មាស | **១ ដល់ ៣ ឆ្នាំ** | មាត្រា ២៤៦ |

**បទល្មើស ឬប្រាក់ពិន័យផ្សេងទៀតអាចជាប់ពាក់ព័ន្ធ ។**
ករណីខ្លះ មានស្ថានទម្ងន់ទោស ដែលអាចដាក់ទោស**ជាប់ពន្ធនាគារ រហូតដល់៣០ឆ្នាំ ។**

# តើខ្ញុំមានសិទ្ធិអ្វីខ្លះ ?



- **សិទ្ធិរស់នៅដោយ គ្មានអំពើហិង្សា**
- **សិទ្ធិដាក់ពាក្យបណ្ដឹង** ទៅអាជ្ញាធរ
- **សិទ្ធិទាមទារសំណង** តាមរយៈតុលាការ



**សិទ្ធិមានមេធាវី** អ្នកអាចស្នើសុំមេធាវីពីអង្គការមិនមែនរដ្ឋាភិបាល សេវាជំនួយផ្នែកច្បាប់ផ្សេងទៀត ឬជួលមេធាវីឯកជន ។

**សិទ្ធិស្នើសុំសវនាការជាអសាធារណៈ**

# តើខ្ញុំអាចស្វែងរកយុត្តិធម៌ដោយរបៀបណា?



អ្នកអាចដាក់ពាក្យបណ្តឹងទៅ៖

**១** **នគរបាល (ប៉ូលិស) នៅទីតាំងកើតហេតុ**
(ដោយឥតគិតថ្លៃ)

**២** **សាលាដំបូងខេត្ត ឬរាជធានី**
ដោយផ្ទាល់ទៅព្រះរាជអាជ្ញា

**៣** **សាលាឧទ្ធរណ៍**
ដើម្បីប្តឹងជំទាស់នឹងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា



**ការធ្វើកោសល្យវិច័យផ្លូវភេទ ជាញឹកញាប់ត្រូវបានប្រើជាភស្តុតាងសំខាន់ក្នុងតុលាការ ។**

បើអ្នកធ្លាប់រងគ្រោះពីអំពើហិង្សាផ្លូវភេទ វាមានសារៈប្រយោជន៍ណាស់ក្នុងការធ្វើកោសល្យវិច័យឱ្យបានឆាប់បំផុត ។ ការធ្វើកោសល្យវិច័យនេះ គឺឥតគិតថ្លៃ និងមានតែនៅមន្ទីរពេទ្យបង្អែកខេត្ត ឬរាជធានី ប៉ុណ្ណោះ ។



**ភស្តុតាងផ្សេងទៀតអាចគាំទ្រករណីរបស់អ្នក ។**

បើមានសុវត្ថិភាព សូមកត់ត្រាព័ត៌មានលម្អិតពីអត្តសញ្ញាណជនល្មើស ពេលវេលា និងទីកន្លែងដែលអំពើហិង្សាបានកើតឡើង សាក្សី រូបថតស្នាមរបួស ឬការខូចខាតទ្រព្យសម្បត្តិ លទ្ធផលពិនិត្យ ឬបង្កាន់ដៃពីពេទ្យ សម្លៀកបំពាក់ដែលពាក់ព័ន្ធ ឬសារទំនាក់ទំនងគ្នា ។

# តើប៉ូលិសត្រូវធ្វើអ្វីខ្លះ ?



**ប៉ូលិសត្រូវតែ៖**

**ទទួល និងចាត់វិធានការលើពាក្យបណ្ដឹងរបស់អ្នក ។** អំពើហិង្សាផ្លូវភេទ ជាបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរ ។ ក្រោយពីទទួលបានពាក្យបណ្ដឹង ប៉ូលិសអាចស៊ើបអង្កេត ឬបញ្ជូនព័ត៌មានទៅព្រះរាជអាជ្ញា ។

**បញ្ជូនអ្នកទៅធ្វើកោសល្យវិច័យផ្លូវភេទ** និងគួរតែណែនាំអ្នកទៅកាន់សេវាជំនួយនានា ។

**ប៉ូលិសត្រូវទទួលខុសត្រូវ ក្នុងករណីមិនអនុវត្តតាមតួនាទី ។**
ប្រសិនបើប៉ូលិសមិនបញ្ជូនសំណុំរឿងព្រហ្មទណ្ឌ
ដែលមានភស្តុតាងនៃអំពើហិង្សាផ្លូវភេទទៅតុលាការ
នោះពួកគាត់នឹងត្រូវផ្ដន្ទាទោសតាមច្បាប់
(មាត្រា ៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ។

អំពើហិង្សាផ្លូវភេទ មិនមែនជា
កំហុសរបស់អ្នកទេ ។
អ្នកមិនគួរទទួលរងការស្តីបន្ទោស
ពីបញ្ហានេះឡើយ ។



បើអាជ្ញាធរមិនចាត់វិធានការលើពាក្យបណ្ដឹងរបស់អ្នកទេ អ្នកអាចស្នើសុំប្រឹក្សាយោបល់ពីអង្គការមិនមែនរដ្ឋាភិបាល ឬអាជ្ញាធរពាក់ព័ន្ធផ្សេងទៀត ។

# ព័ត៌មានទំនាក់ទំនង

អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) តាមរយៈលេខ៖

**០១២ ៥៣៦ ៣០០ ឬ ០១៥ ៥៥៣ ៨៥៥**

សម្រាប់ព័ត៌មានបន្ថែម

សូមចូលទៅកាន់គេហទំព័រ **សុវត្ថិភាព និង យុត្តិធម៌**

www.licadho-cambodia.org/safety-and-justice

លីកាដូ

LICADHO